


*ដោយៈ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា*

ជាទូទៅ កសិករនៅប្រទេសកម្ពុជាធ្វើការដាំដុះដំណាំស្រូវវស្សាបានតែមួយដងប៉ុណ្ណោះ បន្ទាប់មកទុកដីស្រែឲ្យទំនេរពេញមួយរដូវប្រាំង ដោយសារពុំមានទឹកស្រោចស្រព។ អាស្រ័យហេតុនេះ គ្រួសារកសិករភាគច្រើនដែលមានដីស្រែទំហំតូចបានជួបនឹងការខ្វះខាតស្បៀងស្ទើរតែរៀងរាល់ឆ្នាំ និងជាពិសេស នៅពេលដែលដំណាំស្រូវរងការបំផ្លាញពី គ្រោះរាំងស្ងួត ទឹកជំនន់ ឬក៏សត្វល្អិតចង្រៃ និងជំងឺផ្សេងៗ។ ទន្ទឹមនឹងនេះ កសិករមានលទ្ធភាពតិចតួចណាស់ ក្នុងការពង្រីកផ្ទៃដីដាំដុះរបស់ខ្លួន និងអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់សម្រាប់មូលដ្ឋានខ្លួន។ ផ្ដើមចេញពីនេះ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី) នៅឆ្នាំ ១៩៩៦ បានសិក្សាពីប្រព័ន្ធកសិកម្មចម្រុះមួយមានឈ្មោះថា ប្រព័ន្ធកសិកម្មសួរយ៉ាន ដោយជីកជាស្រះ និងប្រឡាយសម្រាប់ចិញ្ចឹមត្រី ព្រមទាំងស្រោចស្រព លើកជាថ្នាលសម្រាប់ដំណាំបន្លែ និងឈើហូបផ្លែ និងរក្សាដីមួយផ្នែកសម្រាប់ដំណាំស្រូវ។

## ទស្សនៈនៃប្រព័ន្ធកសិកម្មគំរូ

ប្រព័ន្ធកសិកម្មគំរូ ត្រូវបានបង្កើតឡើងដោយយកប្រព័ន្ធកសិកម្មសួរយ៉ានជាមូលដ្ឋាន និងផ្អែកលើគោលការណ៍សំខាន់បីគឺ ១-ផ្ទៃដីសម្រាប់ដាំដុះ ២-ប្រភពទឹកសម្រាប់ស្រោចស្រពបន្ថែម និង ៣-កម្លាំងពលកម្មគ្រួសារ ដែលតាំងទីលំនៅផ្ទាល់ក្នុងប្រព័ន្ធ។ គោលបំណងរបស់ប្រព័ន្ធកសិកម្មគំរូ គឺកែលម្អជីវភាពកសិករក្រីក្រ តាមរយៈការបង្កើតឲ្យមាននូវចំណែកដីសម្រាប់ដំណាំស្រូវ បន្លែ ឈើហូបផ្លែ និងចិញ្ចឹមសត្វ ដោយប្រើប្រាស់ទឹកពីក្នុងស្រះ និងប្រឡាយដែលចិញ្ចឹមត្រី លើដីស្រែទំហំតូចដែលគាត់ធ្លាប់តែដាំដុះស្រូវនារដូវវស្សាម្ដងគត់កន្លងមក។ ដូច្នេះ ស្រះ ប្រឡាយ និងអណ្ដូងបុក មានតួនាទីដ៏សំខាន់សម្រាប់ដាំដុះដំណាំ និងចិញ្ចឹមសត្វទាំងក្នុងរដូវប្រាំង និងវស្សារបស់ប្រព័ន្ធកសិកម្មគំរូ (រូបភាពទី ១)។ នៅឆ្នាំ ២០០៧ កាឌី និងសកលវិទ្យាល័យគ្វីនស្លិន ដោយមានការផ្ដល់ថវិកាពី អេស៊ីអាយអេអ័រ របស់ប្រទេសអូស្ត្រាលី បានអភិវឌ្ឍ ប្រព័ន្ធកសិកម្មគំរូនៅខេត្តតាកែវ កំពង់ធំ និងកំពង់ចាម។




*រូបភាពទី ១ គំនូសបំព្រួញប្រព័ន្ធកសិកម្មគំរូ*

## ករណីសិក្សាប្រព័ន្ធកសិកម្មគំរូនៅខេត្តតាកែវ

**ក្នុង**ខេត្តតាកែវ កសិករមួយគ្រួសារមានសមាជិក ៦ នាក់ (ប្ដី ប្រពន្ធ និងកូនតូចៗ ៤ នាក់) ដែលមានផ្ទៃដីលំនៅដ្ឋាន ៣៧៥ ម$^{២}$ និងផ្ទៃដីស្រែវស្សា ៥០២៥ ម$^{២}$ (សរុប ៥.៤០០ ម$^{២}$) នៅភូមិស្រម៉ុក ឃុំពន្លៃ ស្រុកអង្គរបូរី បានស្ម័គ្រចិត្តអនុវត្តប្រព័ន្ធកសិកម្មគំរូ។ ជារៀងរាល់ឆ្នាំ គ្រួសារនេះដាំដុះពូជស្រូវផ្កាខ្ញី និងក្រហមធ្ងន់ ហើយបានផលស្រូវយ៉ាងច្រើនបំផុតតែ ១.២០០ គ.ក្រ (២,៣ តោន ក្នុងមួយហិកតា) ប៉ុណ្ណោះ ដោយក្នុងនោះ គាត់ដកទុកពូជចំនួន ៥០ គ.ក្រ។ បរិមាណផលស្រូវ

នេះ គ្រួសាររបស់គាត់ហូបមិនបានគ្រប់គ្រាន់ទេ ទោះបីជាក្នុងករណីដែលគាត់ទុកហូបទាំងអស់ក៏ដោយ ក៏គ្រួសារគាត់ត្រូវខ្វះស្រូវយ៉ាងតិចបំផុត ២០០ គ.ក្រ ទៀតដែរក្នុងមួយឆ្នាំៗ។

ដោយអនុវត្ត នូវប្រព័ន្ធកសិកម្មគំរូ កសិករបានបែងចែកដីដែលគាត់មានសរុបចំនួន ០,៥៤ ហ.ត ជាដីសម្រាប់លំនៅដ្ឋាន ដំណាំផ្សេងៗ និងការចិញ្ចឹមសត្វចំនួន ៣១ ភាគរយ, ផ្ទៃប្រឡាយចំនួន ១០ ភាគរយ, ស្រះចំនួន ៤ ភាគរយ និងសម្រាប់ដំណាំស្រូវចំនួន ៥៥ ភាគរយ។ អណ្តូងបុកមួយ និងម៉ាស៊ីនបូមទឹកធុនតូចមួយ ជាប្រភពស្រោចស្រពបន្ថែម។ ប្រព័ន្ធកសិកម្មនេះ ត្រូវពឹងផ្អែកទាំងស្រុងលើកម្លាំងពលកម្មគ្រួសារដែលមានពីរនាក់ប្តីប្រពន្ធ និងកូនក្រោមកម្លាំងពលកម្មចំនួន ៤ នាក់។ កម្លាំងពលកម្មសំខាន់គឺប្តី និងមានការចូលរួមយ៉ាងសកម្មពីប្រពន្ធ ព្រមទាំងកម្លាំងបន្ទាប់បន្សំរបស់កូន។

## សារប្រយោជន៍ប្រព័ន្ធកសិកម្មគំរូ

ស្រះ និងប្រឡាយទឹកផ្តល់ប្រយោជន៍ដល់ការចិញ្ចឹមត្រីបាន ២៣០០ ក្បាល និងទឹកសម្រាប់ស្រោចស្រពដំណាំ ព្រមទាំងទឹកសម្រាប់សត្វផឹក។ កសិករដាំស្រូវបានពីរដង ដោយដាំស្រូវដើមរដូវវស្សាបាន ១៩ អារ ដោយប្រើប្រាស់ទឹកបានមកពីអណ្តូងបុក និងស្រះ និងស្រូវវស្សាបាន ៣០ អារ។ ដីទួលនៅជុំវិញលំនៅដ្ឋានរួមទាំងដីខ្នងប្រឡាយអាចដាំបន្លែ ឈើហូបផ្លែ កន្ទុំថេត និងស្មៅគោ។ ភាពអំណោយផលចំណី ផ្តល់លទ្ធភាពឲ្យកសិករចិញ្ចឹមគោបាន ៧ ក្បាល មាន់ចំនួន ១៥០ ក្បាល និងទាមួយចំនួន។ ទន្ទឹមនឹងនេះ កសិករក៏បានចូលរួមសាកល្បងដាំសណ្តែកដី និងសណ្តែកបាយ ដើម្បីជាប្រយោជន៍បានជាថវិកា បង្កើនជីជាតិដីស្រែ និងរក្សាសំណើមដីផងដែរ។

## លទ្ធផលឆ្នាំទី ១ នៃប្រព័ន្ធកសិកម្មគំរូ

ភោគផលពីប្រព័ន្ធកសិកម្មគំរូទាំងអស់ត្រូវបានបរិភោគ និងដោះដូរជាថវិកាសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ តែបើគិតជាប្រាក់ចំណូលសរុបគឺចំនួន ៧.៩៦៥.០០០ រៀល នៅឆ្នាំដំបូង។ ការចិញ្ចឹមសត្វបានផ្តល់ប្រាក់ចំណូលខ្ពស់បំផុតរហូតដល់ ៣,៧ លានរៀល បន្ទាប់មកត្រី ១,៩ លានរៀល និងស្រូវបាន ១,៧៦៥ លានរៀល ព្រមទាំងដំណាំផ្សេងៗក៏បានផ្តល់កម្រៃ ៦ សែនរៀលផងដែរ ដោយឡែកដំណាំឈើហូបផ្លែមិនទាន់ផ្តល់ផល (រូបភាពទី ២)។ ប្រការដែលត្រូវកត់សម្គាល់គឺ តាមរយៈការប្រើប្រាស់ពូជស្រូវផ្ការំដួល ផ្កាច័ន្ទសែនសរ និងរាំងជ័យ ព្រមទាំងបច្ចេកទេសដាំដុះរបស់កាឌី លើដីស្រែវស្សា ៣០ អារ កសិករបានទទួលផលស្រូវ ១.០៥០ គ.ក្រ បើគិតជាទិន្នផលគឺ ៣,៥ តោន ក្នុងមួយហិកតា។ ចំណែកឯស្រែដើមរដូវចំនួន ១៩ អារ វិញ កសិករប្រមូលផលបានចំនួន ៧២០ គ.ក្រ បើគិតជាទិន្នផលគឺ ៣,៨ តោន ក្នុងមួយហិកតា ដោយប្រើប្រាស់ពូជស្រូវសែនពិដោរ និងអ៊ីអ៊ែរ៦៦។ គិតជាសរុប កសិករប្រមូលផលស្រូវបានចំនួន ១.៧៦៥ គ.ក្រ ដែលអាចហូបចុកបានគ្រប់គ្រាន់ និងនៅសល់ពីទុកពូជប្រហែល ៤០០ គ.ក្រ ទៀតផង។ ដូច្នេះប្រព័ន្ធកសិកម្មគំរូអាចធ្វើឲ្យប្រសើរឡើងនូវជីវភាពខ្សត់ខ្សោយរបស់កសិករដែលមានដីស្រែទំហំតូច។



រូបភាពទី ២ ចំណូលពីប្រព័ន្ធកសិកម្មគំរូ


រូបភាពទី ៣ ការពិភាក្សាពីផែនការសម្រាប់ឆ្នាំ ២០១០